អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន

## អ.វ.ត.ក. (ECCC) និង ស្ថាប័នផ្សព្វផ្សាយអប់រំកម្ពុជា (EBC) ចុះអនុស្សរណៈនៃការយោគយល់គ្នា ដើម្បីផលិតមាតិកាអប់រំឌីជីថល

ភ្នំពេញ ប្រទេសកម្ពុជា – អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) និង ស្ថាប័នផ្សព្វផ្សាយអប់រំកម្ពុជា(EBC) នៅថ្ងៃនេះ ចុះអនុស្សរណៈនៃការយោគយល់គ្នា លើកិច្ចសហប្រតិបត្តិការ ដើម្បីផលិតនិងផ្សព្វផ្សាយមាតិកាអប់រំឌីជីថល ដែលមានគោលបំណងអប់រំសាធារណជន អំពីការជំនុំជម្រះក្តី ផ្សព្វផ្សាយអំពីសមិទ្ធផល ការងារ និងកេរដំណែលរបស់ អ.វ.ត.ក.។

ឯកឧត្តម **ក្រាញ់ តូនី** ប្រធានរដ្ឋបាលស្តីទីនៃ អ.វ.ត.ក. មានប្រសាសន៍ថា៖ «អនុស្សរណៈនៃការយោគយល់គ្នា ដែលបានចុះហត្ថលេខានៅថ្ងៃនេះ គឺជាផ្នែកមួយនៃការអនុវត្តមុខងារសេសសល់ ហើយវាជាផ្នែកមួយនៃការងារផ្សព្វផ្សាយព័ត៌មានដើម្បីអប់រំសាធារណជន ក៏ដូចជាផ្សព្វផ្សាយអំពីការងារនិងកេរដំណែលរបស់ អ.វ.ត.ក.»។ លោកមានប្រសាសន៍បន្ថែមថា៖ «មាតិកាវីដេអូ ដែលយើងនឹងសហការផលិតជាមួយ EBC នេះ នឹងប្រើប្រាស់ជាឧបករណ៍អប់រំនិងផ្សព្វផ្សាយ ដែលខ្លឹមសាររបស់វីដេអូ គឺដកស្រង់ចេញពីឯកសារ កំណត់ត្រា និងបណ្ណសារ ដែលរំលេចនូវប្រធានបទជាច្រើនទាក់ទងនឹងការជំនុំជម្រះក្តី និងការស៊ើបអង្កេតក្តីក្នុងរយៈពេល១៦ឆ្នាំ។ វីដេអូអប់រំទាំងនេះ នឹងក្លាយជាផ្នែកសំខាន់មួយនៃសកម្មភាពអប់រំ ក្នុងគោលបំណងផ្សព្វផ្សាយអំពីការងាររបស់ អ.វ.ត.ក. សម្រាប់យុវជនជំនាន់ក្រោយ។

ឯកឧត្តម **សុខ ពុទ្ធិវុធ** រដ្ឋលេខាធិការនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និង ជាប្រធានគណៈកម្មការគ្រប់គ្រងគម្រោងស្តីពីការបង្កើតនិងប្រតិបត្តិការថ្នាលអប់រំដោយប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ ព័ត៌មាននិងប្រព័ន្ធផ្សព្វផ្សាយ មានប្រសាសន៍ថា៖ «ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នានៅថ្ងៃនេះ នឹងជំរុញកិច្ចសហប្រតិបត្តិការនិងការអនុវត្តគម្រោងរួមគ្នារវាង EBC និង ECCC ដែលនឹងផ្តោតលើការផលិតមាតិកាឌីជីថល ឯកសារវីដេអូ និងការផ្សព្វផ្សាយ ពាក់ព័ន្ធនឹងដំណើរការកាត់សេចក្តីនៃអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដើម្បីជំរុញការយល់ដឹងពីគុណតម្លៃនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ទាំងអ្នកដែលបានបាត់បង់ជីវិតទៅ ទាំងអ្នកនៅរស់ដល់សព្វថ្ងៃនេះ»។ លោកមានប្រសាសន៍បន្តថា៖ «ការផលិតមាតិការឌីជីថលនិងកិច្ចការងារផ្សព្វផ្សាយនេះ នឹងជួយឲ្យក្មេងជំនាន់ក្រោយអាចដឹងការពិតទាក់ទងនឹងអ្វីដែលបានកើតឡើងនៅក្រោមរបបខ្មែរក្រហម»។

សូមបញ្ជាក់ថា មាតិកាវីដេអូមួយផ្នែក ដែលគ្រោងនឹងផលិតនេះ នឹងផ្តោតលើសេចក្តីថ្លែងការណ៍របស់ជនរងគ្រោះ ដែលបានធ្វើឡើងក្នុងអំឡុងពេលសវនាការកាត់សេចក្តី ដែលមានលំនាំតាមកម្មវិធីទូរស្សន៍ «រឿងរបស់ខ្ញុំ» ឬ My Story។ បើតាមអនុស្សរណៈនៃការយោគយល់គ្នានេះ អ.វ.ត.ក. មានភារកិច្ចជាចម្បងសម្រាប់ដំណាក់កាលដំបូង ចាប់ពីការរៀបចំបង្កើតខ្លឹមសារ

សាច់រឿង និងការប្រមូលព័ត៌មាន រហូតដល់ការជ្រើសរើសតួអង្គ និងការសរសេរសាច់រឿង ខណៈដែល EBC ទទួលខុសត្រូវចំពោះដំណាក់កាលចុងក្រោយ ចាប់ពីការថត និងការកាត់ត រហូតដល់ការចែកចាយ និងការផ្សព្វផ្សាយ។

###

**កំណត់ចំណាំចំពោះបណ្ណាធិការព័ត៌មាន៖**

- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.) គឺជាស្ថាប័នតុលាការក្នុងស្រុកមួយ ដែលត្រូវបានបង្កើតឡើងស្របតាមច្បាប់ប្រទេសកម្ពុជា។ អ.វ.ត.ក. មានយុត្តាធិការក្នុងការជំនុំជម្រះក្តីមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្ម និងការរំលោភធ្ងន់ធ្ងរ នៃក្រមព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ បន្ទាប់ពីបញ្ចប់ដំណើរការកាត់ក្តីរបស់ខ្លួន អ.វ.ត.ក. បានចាប់ផ្តើមនៅខែមករា ឆ្នាំ២០២៣ ដើម្បីអនុវត្តលើមុខងារដែលនៅសេសសល់សម្រាប់រយៈពេលបីឆ្នាំដំបូង ស្របតាមកិច្ចព្រមព្រៀងបន្ថែមរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ។

- ស្ថាប័នផ្សព្វផ្សាយអប់រំកម្ពុជា (EBC) គឺជាស្ថាប័នផ្សព្វផ្សាយការអប់រំដំបូងគេបង្អស់នៅក្នុងប្រទេសកម្ពុជា។ EBC ទទួលបានការគាំទ្រពីសំណាក់ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងព័ត៌មាន ដោយមានការគាំទ្របច្ចេកទេសពីស្ថានីយទូរទស្សន៍អប់រំកូរ៉េ (EBS) និងជំនួយផ្នែកហិរញ្ញវត្ថុពីក្រសួងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាគមនាគមន៍ (MSIT) នៃសាធារណរដ្ឋកូរ៉េ។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖**

លោក **គុណ ចិន្តា**
មន្ត្រីទទួលបន្ទុកផ្នែកព័ត៌មាន ផ្នែកកិច្ចការសាធារណៈ
លេខទូរស័ព្ទទំនាក់ទំនង៖ +៨៥៥ (០)១២ ៣៣៦ ០៩៧
អ៊ីម៉ែល៖ kun.chenda@eccc.gov.kh

**សម្រាប់ព័ត៌មានបន្ថែមទៀត៖**

- គេហទំព័រ អ.វ.ត.ក. ៖ https://eccc.gov.kh/
- គេហទំព័រ EBC ៖ https://ebc.edu.kh/